គណៈកម្មាធិការ
សហប្រតិបត្តិការដើម្បីកម្ពុជា

Cooperation Committee
for Cambodia

Comité de Coopération
Pour le Cambodge

# លក្ខន្តិកៈ

## គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

កំណែប្រែ ៖០៨ សីហា ២០១៤

សីហា ២០១៤

ភាពជាដៃគូសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅកម្ពុជា

# មាតិកា


**សេចក្តីផ្តើម:** 1

**ប្រការ ១ : ឈ្មោះ និងគោលដៅ** 1

**ប្រការ ២: រូបសញ្ញា និងត្រា** 2

**ប្រការ ៣: ទីស្នាក់ការ ឬ ការិយាល័យ** 3

**ប្រការ ៤: រចនាសម្ព័ន្ធនៃអង្គការ គសក** 3

**ប្រការ ៥: សមាជិកភាព** 3

៥.១. សមាជិកភាព 3

៥.២. ប្រភេទនានានៃសមាជិកភាព 3

៥.៣. លក្ខណៈសមស្របនៃសមាជិកភាព 4

៥.៤. បែបបទដាក់ពាក្យសុំចូលជាសមាជិក 4

៥.៥. ទម្រង់បេក្ខភាព 6

៥.៦. សិទ្ធិ និងភារកិច្ចនៃសមាជិកភាព 6

៥.៧. ការបញ្ឈប់សមាជិកភាព 7

៥.៨. អំពីកិច្ចប្រជុំ 8

៥.៩. គូរ៉ុម (ចំនួនចាំបាច់ដើម្បីដំណើរការកិច្ចប្រជុំ) 8

៥.១០. ការផ្ទេរសិទ្ធិជំនួស (PROXIES) 9

៥.១១. អំពីការបោះឆ្នោត 9

**ប្រការ ៦: គណៈកម្មាធិការប្រតិបត្តិ** 10

៦.១. តួនាទីរបស់គណៈកម្មាធិការប្រតិបត្តិ 10

៦.២. ភារកិច្ចផ្សេងៗ នៃគណៈកម្មាធិការប្រតិបត្តិ 10

៦.៣. កាតព្វកិច្ចផ្សេងៗរបស់សមាជិក នៃគណៈកម្មាធិការប្រតិបត្តិ 11

៦.៤. នីតិវិធីនៃការបោះឆ្នោត សម្រាប់គណៈកម្មាធិការប្រតិបត្តិ 12

៦.៥. បែបបទការងារ 13

៦.៦. កំណត់ហេតុនៃកិច្ចប្រជុំ និង វត្តមាន 13
៦.៧. ការរំសាយនៃគណៈកម្មាធិការប្រតិបត្តិ 14
**ប្រការ ៧: គណៈកម្មការនានា** 14
៧.១. ការតែងតាំងគណៈកម្មការនានា ( ក្រៅពីគណៈកម្មាធិការប្រតិបត្តិ) 14
៧.២. សិទ្ធិចូលរួមនៅក្នុងគណៈកម្មការនានា 15
**ប្រការ ៨: នាយកប្រតិបត្តិ នៃអង្គការ គសក** 16
**ប្រការ ៩: ហិរញ្ញវត្ថុ** 17
៩.១. ថវិការបស់អង្គការ គសក 17
៩.២. ការប្រើប្រាស់ថវិកា 18
៩.៣. គម្រោងចំណាយថវិកា 18
៩.៤. គម្រោងថវិកាប្រចាំឆ្នាំ 18
៩.៥. ការចំណាយនានា 18
៩.៦. កម្រៃសមាជិកភាព 18
៩.៧. ការរៃអង្គាសថវិកា 19
៩.៨. អំណោយពីប្រភពដែលពុំមែនជាសមាជិកអង្គការ 19
៩.៩. របាយការណ៍ហិរញ្ញវត្ថុ 19
៩.១០. ការធ្វើសវនកម្ម 19
**ប្រការ ១០: ការរំលាយ និងការចាត់ចែងទ្រព្យសម្បត្តិនៅពេលដែលត្រូវរំលាយអង្គការ** 19
១០.១. ការរំលាយអង្គការ 19
១០.២. ការចាត់ចែងទ្រព្យសម្បត្តិនៅពេលដែលត្រូវរំលាយអង្គការ 19
**ប្រការ ១១: ការធ្វើវិសោធនកម្មលក្ខន្តិក** 20

## សេចក្តីផ្តើម:

ចាប់តាំងពីឆ្នាំ ១៩៧៩ មក សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលដែលអនុវត្តការងារដោយពុំយកផលចំណេញ បានធ្វើសកម្មភាពបម្រើប្រជាពលរដ្ឋកម្ពុជាយ៉ាងសកម្មក្នុងការផ្សះផ្សា ការស្តារ និងស្ថាបនាប្រទេសកម្ពុជាឡើងវិញ តាមរយៈការផ្តល់ជំនួយមនុស្សធម៌ ការអភិវឌ្ឍ ការផ្តល់ជំនាញបច្ចេកទេស និងធនធាន ព្រមទាំងការលើកកម្ពស់ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គសក) ឬជាភាសាអង់គ្លេសថា Cooperation Committee for Cambodia (CCC) និងជាភាសាបារាំង "Comité de Coopération pour le Cambodge" បានបង្កើតឡើងនៅឆ្នាំ ១៩៩០ ជាអង្គការសមាជិកភាពឈានមុខគេសម្រាប់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិនៅក្នុងប្រទេសកម្ពុជា។ គសក បានកំពុងដើរតួនាទីជាអ្នកសម្របសម្រួល កសាងបណ្តាញ និងតស៊ូមតិ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ វិជ្ជាជីវៈ គណនេយ្យភាព អភិបាលកិច្ច និងប្រសិទ្ធភាពនៃការអភិវឌ្ឍរបស់អង្គការសង្គមស៊ីវិល ដែលកំពុងធ្វើការនៅចម្រុះវិស័យ ព្រមទាំងជំរុញឱ្យមានបរិយាកាសអំណោយផលសម្រាប់រាល់តួអង្គអភិវឌ្ឍដើម្បីការអភិវឌ្ឍប្រទេសកម្ពុជាប្រកបដោយនិរន្តរភាព។

## ប្រការ ១ : ឈ្មោះ និងគោលដៅ

១.១ តទៅនេះ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា នឹងត្រូវទទួលស្គាល់ និងហៅកាត់ថា "**អង្គការគសក**" ។ ជាមួយគ្នានេះ ពាក្យថា សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ជាបន្តបន្ទាប់គឺហៅកាត់ថា "**អង្គការសង្គមស៊ីវិល**" ។

១.២ **ទស្សនវិស័យ:** ការអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់ប្រទេសកម្ពុជា។

ពាក្យស្លោក: ភាពជាដៃគូដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាពក្នុងប្រទេសកម្ពុជា។

១.៣ **បេសសកម្ម:**យើងផ្តល់នូវសេវាកម្មប្រកបដោយគុណភាពខ្ពស់ជូនដល់សង្គមស៊ីវិល និងបង្កលក្ខណៈ ឱ្យមានឥទ្ធិពលទៅដល់តួអង្គអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា ។

១.៤ **គោលដៅ** សង្គមស៊ីវិលមួយដែលមានកិច្ចសហការដ៏រឹងមាំ និងមានសមត្ថភាពឆ្លើយតបទៅនឹងបញ្ហា នៃការអភិវឌ្ឍនៅកម្ពុជា ។

១.៥ គោលបំណងនៃអង្គការ គសក គឺមានចែងដូចខាងក្រោមនេះ៖

១.៥.១ លើកកម្ពស់កិច្ចសហប្រតិបត្តិការ និងសំឡេងរួមរបស់អង្គការសង្គមស៊ីវិលគ្រប់ប្រភេទ ដែលមានសកម្មភាពនៅកម្ពុជា ព្រមទាំងពង្រឹងគុណភាពសេវារបស់ពួកគេ។

១.៥.២ លើកកម្ពស់អភិបាលកិច្ចល្អ វិជ្ជាជីវៈ និងប្រសិទ្ធភាពរបស់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា។

១.៥.៣ ជំរុញឱ្យមានបរិយាកាសអំណោយផល និងភាពជាដៃគូបរិយាប័ន ជាមួយរាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសង្គមស៊ីវិលក្នុងការឆ្លើយតបទៅនឹងបញ្ហានានាដែលជាផល

ប្រយោជន៍រួម។

## ១.៦ គុណតម្លៃ

រាល់គោលនយោបាយ កម្មវិធី និងសកម្មភាពរបស់អង្គការ គសក នឹងគោរពតាមគុណតម្លៃដូចខាងក្រោម៖

- សុចរិតភាព
- ភាពឆ្លើយតប
- កិច្ចសហប្រតិបត្តិការ
- គុណភាព
- បរិយាប័ន

# ប្រការ ២: រូបសញ្ញា និងត្រា

២.១ អង្គការ គសក មានរូបសញ្ញាផ្តុំ ដោយប្រអប់បួនជ្រុង (រាងចតុកោណកែង) បញ្ឈរចំនួនបី (៣) ប្រអប់កណ្តាលមានពណ៌ទឹកប៊ិច (ខៀវចាស់) ដែលមានអក្សរនៅក្នុងប្រអប់បន្តគ្នាពីលើចុះក្រោមជាភាសាខ្មែរ "គសក" និងមានអក្សរឡាតាំង "CCC" ហើយអមដោយប្រអប់បួនជ្រុងពីរ (២) មានពណ៌បៃតង និងនៅផ្នែកខាងស្តាំដៃនៃប្រអប់បួនជ្រុងបញ្ឈរទាំងបីមានដាក់ឈ្មោះពេញរបស់អង្គការជាបីភាសាគឺ៖

- ជាភាសាខ្មែរ "គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា" (នៅខាងលើ)
- ជាភាសាអង់គ្លេស "Cooperation Committee for Cambodia" (នៅកណ្តាល) និង
- ជាភាសាបារាំង " Comité de coopération pour le Cambodge" (នៅខាងក្រោម) ដូចមានសញ្ញារូបភ្ជាប់ជូនខាងក្រោម:

២.២ ត្រារបស់អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គសក) ជាតារាងមូលទំហំ៣៩ម.ម. ប្រើទឹកលក្ខ័ពណ៌ខៀវ។ ត្រាមូលនេះមានរង្វង់មូលមួយនៅផ្នែកខាងក្រៅ និងនៅផ្នែកខាងក្នុងមានរង្វង់មូលមួយ ហើយនៅចន្លោះរង្វង់ទាំងពីរមានអក្សរជាភាសារខ្មែរ "អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា" នៅផ្នែកពាក់កណ្តាលរង្វង់មូលផ្នែកខាងលើ និងមានអក្សរអង់គ្លេស "Cooperation Committee for Cambodia" នៅពាក់កណ្តាលរង្វង់មូលផ្នែកខាងក្រោម។ នៅក្នុងរង្វង់មូលផ្នែកខាងក្នុងមានប្រអប់បួនជ្រុងបញ្ឈរចំនួនបី ហើយមានអក្សរនៅក្នុងប្រអប់បន្តគ្នាពីលើចុះក្រោមជាអក្សរខ្មែរ "គសក" និងជាអក្សរឡាតាំង "CCC" ដូចមានរូបសញ្ញាភ្ជាប់ជូនខាងក្រោម:

## ប្រការ ៣:  ទីស្នាក់ការ ឬ ការិយាល័យ

អង្គការ គសក មានទីស្នាក់ការបណ្ដោះអាសន្នស្ថិតនៅអគារលេខ ៩-១១, ផ្លូវលេខ ៤៧៦, សង្កាត់ ទួលទំពូង ១, ខណ្ឌចំការមន, ប្រអប់សំបុត្រលេខ ៨៥៥, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា ។ ការិយាល័យសាខានៅតាមបណ្ដាខេត្តនានានៃព្រះរាជាណាចក្រកម្ពុជានឹងអាចមានឡើងក្នុងករណីចាំបាច់។

## ប្រការ ៤: រចនាសម្ព័ន្ធនៃអង្គការ គសក

អង្គការ គសក គឺបែងចែកជា០៤ អង្គភាព: សមាជិកភាព គណៈកម្មាធិការប្រតិបត្តិ គណៈកម្មាធិការផ្សេងៗ និង នាយក/នាយិកាប្រតិបត្តិ បុគ្គលិក និងការិយាល័យ។

## ប្រការ ៥: សមាជិកភាព

### ៥.១ សមាជិកភាព

សមាជិកភាពនៃអង្គការ គសក គឺបើកចំហចំពោះអង្គការសង្គមស៊ីវិលគ្រប់វិស័យ ដែលធ្វើការដើម្បី ផ្ដល់ជំនួយមនុស្សធម៌ លើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ចសង្គម សិទ្ធិមនុស្ស ប្រជាធិបតេយ្យ និរន្តរភាពបរិស្ថាន និងវិស័យផ្សេងៗទៀត ដោយពុំផ្ដោតលើការផ្សព្វផ្សាយ និងធ្វើសកម្មភាពបម្រើសកម្មភាពគណបក្សនយោបាយ ឬ សាសនានិយមជ្រុល។ ប្រភេទ លក្ខណៈវិនិច្ឆ័យ បែបបទដាក់ពាក្យសុំចូលជាសមាជិកភាព គឺមានចែងក្នុងគោលការណ៍ ៥.២; ៥.៣; ៥.៤។ អង្គការ គសក នឹងព្យាយាមធ្វើឱ្យមានការចូលរួមដ៏ទូលំទូលាយបំផុតពីសំណាក់អង្គការសង្គមស៊ីវិលនានាជាសមាជិក និងជាដៃគូ។

### ៥.២ ប្រភេទនានានៃសមាជិកភាព

#### ៥.២.១ សមាជិកពេញសិទ្ធិ

អង្គការសមាជិកជាបេក្ខជនដែលមានលក្ខណៈគ្រប់គ្រាន់ ដូចចែងក្នុងគោលការណ៍ ៥.៣ នៃប្រការ ៥នេះ អាចចូលជាសមាជិកពេញសិទ្ធិ។ និយោជិកនៃអង្គការ ដែលជាសមាជិកពេញសិទ្ធិ អាចឈរឈ្មោះបោះឆ្នោតជាសមាជិកគណៈកម្មាធិការប្រតិបត្តិ និងចូលរួមបម្រើក្នុងគណៈកម្មាធិការនានានៃអង្គការ គសក។

៥.២.២ សមាជិកគាំទ្រ (Associate)

សមាជិកគាំទ្រសំដៅរាល់អង្គការ ដែលមានលក្ខណៈមិនគ្រប់គ្រាន់ដូចចែងក្នុងគោលការណ៍ ៥.៣ នៃប្រការនេះ–អាចចូលជាសមាជិកគាំទ្រ ។ អង្គការដែលជាសមាជិកគាំទ្រ គឺមានសិទ្ធិត្រឹមតែផ្ដល់មតិប៉ុណ្ណោះ។ និយោជកនៃអង្គការដែលមានលក្ខណៈ ជាសមាជិកគាំទ្រអាចចូលរួមបម្រើក្នុងអនុគណៈកម្មាធិការអង្គការ គសក ឬគណៈកម្មាធិការពិសេស។ អង្គការណាដែលមានលក្ខណៈគ្រប់គ្រាន់ចូលជាសមាជិកពេញសិទ្ធិ ពុំអាចជ្រើសខ្លួនចូលជាសមាជិកគាំទ្របានឡើយ។

## ៥.៣ លក្ខណៈសមស្របនៃសមាជិកភាព

៥.៣.១ ត្រូវមានឯកសារបញ្ជាក់ថាជាអង្គការសង្គមស៊ីវិលមិនមែនជារដ្ឋាភិបាល និងពុំមែនរកផលចំណេញ ដើម្បីបម្រើតែផលប្រយោជន៍បុគ្គលនៅក្នុងអង្គការរបស់ខ្លួន។

៥.៣.២ គោលដៅ៖ អង្គការនានាដែលមានគោលដៅចំបង ពាក់ព័ន្ធនឹងការអភិវឌ្ឍ ឬមនុស្សធម៌ ឬការលើកកម្ពស់សិទ្ធិមនុស្ស ប្រជាធិបតេយ្យ និងនិរន្តភាពនៃបរិស្ថាន ហើយមិនផ្ដោតលើការលើកស្ទួយគណបក្សនយោបាយណាមួយ ឬ ប្រកាន់សាសនា។ ក្នុងករណីមានការមន្ទិលសង្ស័យអំពីសកម្មភាពនៃអង្គការណាមួយ អង្គការ គសក រក្សាសិទ្ធិសាកសួរ ហើយតាមដាន និងស្វែងរកការបញ្ជាក់នានា។

៥.៣.៣ ការិយាល័យជាក់លាក់៖ អង្គការត្រូវមានទីតាំងច្បាស់លាស់នៅកម្ពុជាដោយមានតំណាង ទីស្នាក់ការ ឬ ក៏មានបុគ្គលិកប្រចាំការនៅកម្ពុជា ដែលមានសិទ្ធិច្បាស់លាស់ជាតំណាងនៃអង្គការនេះ ហើយដែលមានលទ្ធភាពអាចចូលរួមសកម្មភាពជាមួយអង្គការ គសក។

៥.៣.៤ កម្មវិធី៖ អង្គការត្រូវមានកម្មវិធីដំណើរការនៅកម្ពុជា ឬផ្ដល់ការឧបត្ថម្ភដល់កម្មវិធីក្ដី ដល់អង្គការក្ដី ឬ ការផ្ដួចផ្ដើមគំនិតក្នុងកម្ពុជា ជាលក្ខណៈបច្ចេកទេស ថវិកា និងសម្ភារៈក្នុងគោលបំណងឧបត្ថម្ភអ្វីដែលជាផលប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជា។

៥.៣.៥ ឯកសារជាក់ស្ដែង៖ អង្គការត្រូវផ្ដល់ដើម្បីបញ្ជាក់ថាករណីខាងលើមានភាពសមស្រប។ ឯកសារចាំបាច់នេះ គឺដូចចែងក្នុងគោលការណ៍ ៥.៣.៣ និង ៥.៣.៤ ។

៥.៣.៦ ក្រោយពីបានចូលជាសមាជិកអង្គការគសក សមាជិកពេញសិទ្ធិ ឬ សមាជិកគាំទ្រ ចាំបាច់ត្រូវផ្ដល់ព័ត៌មានជាលាយលក្ខ័អក្សរដល់អង្គការគសក អំពីហិរញ្ញវត្ថុ និងបុគ្គលិក ព្រមទាំងអំពីការផ្លាស់ប្ដូរ ឬ កែប្រែរចនាសម្ព័ន្ធ ឬ លក្ខណៈរបស់ខ្លួនជាប្រចាំឆ្នាំ។

៥.៣.៧ គណៈកម្មាធិការប្រតិបត្តិ ឬ សមាជិកនៃគណៈកម្មាធិការនានា មានសិទ្ធិសាកសួរ ឬ ពិនិត្យលើសមាជិកភាពដោយផ្អែកលើព័ត៌មានផ្ដល់ដោយសាមីអង្គការ ឬ ដោយផ្អែកលើព័ត៌មានដទៃដែលខ្លួនទទួលបាន។

## ៥.៤ បែបបទដាក់ពាក្យសុំចូលជាសមាជិក

៥.៤.១ អង្គការណាដែលមានលក្ខណៈសមស្រប អាចសុំចូលជាសមាជិកសង្កេតការណ៍ រយៈពេលពីរ (២) ខែ ។ ជាសមាជិកអង្កេតការណ៍ អាចមានសិទ្ធិផ្ដល់មតិ បោះឆ្នោត និងចូលរួម អនុវត្តសកម្មភាព

នានា របស់អង្គការ គសក។

៥.៤.២ ក្នុងរយៈពេលពីរ(២)ខែ ជាអ្នកសង្កេតការណ៍អង្គការត្រូវរៀបចំឯកសារសមស្របដើម្បីសុំចូលជាសមាជិកពេញសិទ្ធិ ហើយឆ្លងកាត់ការបោះឆ្នោតអនុម័តទទួលស្គាល់ពីសមាជិកគណកម្មការប្រតិបត្តិក្នុងសំលេង ៥០ បូក១ នៅក្នុងកិច្ចប្រជុំសាមញ្ញរបស់ខ្លួន។

៥.៤.៣ ឯកសារមួយសំណុំនឹងត្រូវទទួលបានពីការិយាល័យអង្គការ គសក ដែលមានរាយនាម ដូចខាងក្រោមនេះ ÷

១) ពាក្យស្នើសុំចូលជាសមាជិក

២) លក្ខន្តិកៈ និង គោលការណ៍ការងារនៃអង្គការ គសក

៣) បញ្ជីរាយឈ្មោះអង្គការដែលជាសមាជិកបច្ចុប្បន្ន

៤) ព័ត៌មានលំអិតអំពីកម្រៃ និងផលប្រយោជន៍នៃសមាជិកភាព ព្រមទាំងឯកសារសំខាន់មួយចំនួនដ៏ទៃទៀត។

៥.៤.៤ ឯកសារដែលត្រូវភ្ជាប់ជាមួយពាក្យសុំចូលជាសមាជិករួមមាន ៖

៥.៤.៤.១ លិខិត ១ច្បាប់ បញ្ជាក់អំពីគោលបំណងចូលជាសមាជិកអង្គការ គសក ជូនដល់នាយក/នាយិកាប្រតិបត្តិ អង្គការ គសក

៥.៤.៤.២ ពាក្យស្នើសុំចូលសមាជិកភាព ត្រូវមាន ÷

១) ឈ្មោះអង្គការ

២) ឈ្មោះតំណាងចាត់តាំង ឬអ្នកតែងតាំងជំនួសដើម្បីចូលរួមប្រជុំនៅអង្គការ គសក

៣) សេចក្តីបញ្ជាក់ ដើម្បីចុះហត្ថលេខាយល់ព្រមគោរពតាមគោលការណ៍ និងលក្ខន្តិកៈអង្គការ គសក

៤) សេចក្តីបញ្ជាក់ដើម្បីចុះហត្ថលេខាអះអាងថា នឹងចូលរួមជាប្រាកដដោយវត្តមានក្តីដោយ ផ្ទេរសិទ្ធិក្តី ក្នុងកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញនៃអង្គការ គសក។

៥) សេចក្តីបញ្ជាក់ថាអង្គការសាមីនឹងបង់ប្រាក់កម្រៃសមាជិកភាពនៅពេលចូល ជាសមាជិកអង្គការ គសក។

៦) ឯកសារផ្លូវការដែលបញ្ជាក់អំពីលក្ខណៈជាអង្គការសង្គមស៊ីវិលដែលមិនមែនជារដ្ឋាភិបាលនិងពុំមានផលចំណេញ (ចេញដោយស្ថាក់ការក្នុងប្រទេស ដែលសាមីអង្គការចុះចូលបញ្ជីជាផ្លូវការ) ករណីការដាក់ពាក្យសុំចូលជាសមាជិកភាពពេញសិទ្ធិ ។

៧) ការពិពណ៌នាអំពីអង្គការរួមមានទស្សនៈ ទិសដៅ ប្រភពថវិកា លក្ខណៈ និងឯកសារ ផ្តល់ព័ត៌មាន ដែលអង្គការប្រើប្រាស់សម្រាប់ការរៃអង្គាសថវិកា តាមរយៈស្នាក់ការកណ្តាល។

៨) ការអធិប្បាយអំពីកម្មវិធីសាមីអង្គការនៅកម្ពុជាដោយបញ្ជាក់អំពីគោលដៅអ្នកទទួលសេវាកម្ម និង គម្រោងថវិកាប្រចាំឆ្នាំ។

## ៥.៥ ទម្រង់បេក្ខភាព

១) នៅពេលទទួលឯកសារដំបូងស្នើសុំចូលជាសមាជិក នាយក/នាយិកាប្រតិបត្តិនឹងជូនដំណឹងដល់គណៈកម្មាធិការប្រតិបត្តិ និងសមាជិកទូទៅអំពីភាពសមស្របនៃអង្គការនោះក្នុងការចូលជាសមាជិកភាព។

២) ក្រោយពេលទទួលបានឯកសារចាំបាច់គ្រប់គ្រាន់ហើយ គណៈកម្មាធិការប្រតិបត្តិវាយតម្លៃ លើសំណើសុំរបស់សមាជិកអង្កេតការណ៍ និងផ្តល់អនុសាសន៍ ថាគួរអញ្ជើញអង្គការអង្កេតការណ៍នោះដាក់ឱ្យគេបោះឆ្នោត ឬ ឱ្យអង្គការនោះដាក់ជូនបន្ថែមនូវឯកសារចំបាច់ទៀត ដើម្បីបញ្ជាក់បន្ថែមពីអង្គការនោះ។

៣) នៅចុងបញ្ចប់នៃដំណាក់កាលអង្កេតការណ៍ គណៈកម្មាធិការប្រតិបត្តិ នឹងបោះឆ្នោតសម្រេចទទួល ឬជំទាស់មិនទទួលឱ្យចូលជាសមាជិកថ្មីដោយសម្លេងភាគច្រើន ៥០%+១។

៤) បើសិនជាទំទាស់ គណៈកម្មាធិការប្រតិបត្តិធ្វើការកត់ត្រាលើលក្ខណៈវិនិច្ឆ័យ ជាក់លាក់ណា ខ្លះសម្រាប់ចូលជាសមាជិកដែលអង្គការនោះមិនបានឆ្លើយតបនៅឡើយ។

៥) បន្ទាប់មក នាយក/នាយិកាប្រតិបត្តិនឹងជូនព័ត៌មានអំពីលទ្ធផលនៃការបោះឆ្នោតដល់សមាជិក។ សេចក្តីសម្រេចចុងក្រោយជាមួយនឹងគោលបំណងសមហេតុផលនឹងត្រូវកត់ត្រានៅក្នុងកំណត់ហេតុ ប្រជុំទូទៅរបស់អង្គការ គសក ។

៦) ការបង់ថ្លៃសមាជិកភាពនឹងតម្រូវឱ្យទាំងសមាជិកពេញសិទ្ធិ និង សមាជិកទាំងគាំទ្រ ធ្វើឡើងនៅពេលដែលអង្គការនោះបានទទួលការសម្រេចឱ្យចូលជាសមាជិកអង្គការ គសក។

៧) សមាជិកអង្កេតការណ៍នឹងតម្រូវឱ្យបង់ថ្លៃនូវចំនួនកំណត់មួយជាក់លាក់ សម្រាប់គ្របដណ្តប់លើសេវាកម្មព័ត៌មាន និងសម្ភារៈផ្សេងៗ ដែលបានផ្តល់ជូននៅអំឡុងពេលជាសមាជិកអង្កេតការណ៍។

## ៥.៦ សិទ្ធិ និងភារកិច្ចនៃសមាជិកភាព

៥.៦.១ ដោយយោងតាមតួនាទីនៃអង្គការ គសក ដែលជាអង្គការសម្របសម្រួលការសម្រេចគោលដៅនៃសមាជិកភាព អង្គការសមាជិកភាពរក្សាសិទ្ធិស្វ័យភាព និងការទទួលខុសត្រូវលើកម្មវិធី និងសកម្មភាពរៀងៗខ្លួន។

៥.៦.២ សិទ្ធិសម្រេចលើគោលការណ៍ដែលពាក់ពន្ធ័នឹងសមាជិកភាពទាំងមូល គឺជាបន្ទុករបស់សមាជិកពេញសិទ្ធិ។

៥.៦.៣ អង្គការដែលជាសមាជិកមានសម្លេងបោះឆ្នោតមួយសម្លេង ក្នុងការបោះឆ្នោតតែងតាំងសមាសភាពនានានៃគណៈកម្មាធិការនិមួយៗ តម្រូវឆ្លងការប្រជុំដែលមានចំនួនចាំបាច់ ដើម្បីបើកអង្គប្រជុំបាន (Quorum)។

៥.៦.៤ បុគ្គលិកនៃអង្គការសមាជិកពេញសិទ្ធិអាចឈរឈ្មោះបោះឆ្នោត ជ្រើសតាំងក្នុងគណៈកម្មាធិការតាមវិស័យផ្សេងៗនៃអង្គការ គសក។

៥.៦.៥ ជាសមាជិកសង្កេត មានសិទ្ធិចូលរួមជាអ្នកសង្កេតការណ៍ក្នុងសកម្មភាពនានា និងគ្រប់កិច្ចប្រជុំប្រចាំពីរខែម្តងរបស់សមាជិកនៃអង្គការ គសក លើកលែងតែកិច្ចប្រជុំនៃគណៈកម្មាធិការប្រតិបត្តិ។

៥.៦.៦ សមាជិកពេញសិទ្ធិ និងសមាជិកគាំទ្រមានសិទ្ធិលើកបញ្ហា ពិភាក្សា និងផ្តល់មតិណែនាំលើរាល់ករណីដែលពាក់ពន្ធ័នឹងសកម្មភាព និងដំណើរការនៃអង្គការ គសក។

៥.៦.៧ សមាជិកពេញសិទ្ធិ និងសមាជិកគាំទ្រអាចពិនិត្យឯកសារគ្រប់ប្រភេទដែលរក្សាទុកនៅការិយាល័យអង្គការ គសក។

៥.៦.៨ សមាជិកទាំងអស់អាចទទួលបាននូវប្រយោជនិជារូបី និងអរូបីជាច្រើន ដូចជាៈ ការភ្ជាប់បណ្តាញជាមួយអង្គការជាតិ និងអន្តរជាតិនានា, ការចែករំលែកព័ត៌មានក្នុងចំណោមអង្គការសមាជិក និងអង្គការសង្គមស៊ីវិលនានា សម្លេងរួមមួយសម្រាប់អង្គការសង្គមស៊ីវិល ការអភិវឌ្ឍអង្គការ និងការរៀនពីគ្នា ការទទួលបានឯកសារបោះពុម្ពនានា និងការប្រើប្រាស់មូលដ្ឋានទិន្នន័យរបស់អង្គការសង្គម ស៊ីវិលលើបណ្តាញអ៊ីនធឺរណេត ការទទួលបានសេវាប្រឹក្សាយោបល់លើបញ្ហាអង្គការមិនមែន រដ្ឋាភិបាលទាំងអស់ ការធ្វើបច្ចុប្បន្នភាពស្តីពីគោលនយោបាយរបស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដែលទាក់ទងអង្គការមិនមែនរដ្ឋាភិបាលនៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។ សម្រាប់ផលប្រយោជន៍លំអិតនឹងមានចែងនៅក្នុងឯកសារដោយឡែក។

## ៥.៧ ការបញ្ឈប់សមាជិកភាព

៥.៧.១ សមាជិកភាពនឹងត្រូវបញ្ឈប់ ក្នុងករណីដូចខាងក្រោម ÷

១) ការបោះឆ្នោតដោយសម្លេងភាគច្រើន ៥០% + ១ ក្នុងចំណោមសមាជិកគណៈកម្មាធិការប្រតិបត្តិបញ្ជាក់ថាសកម្មភាព/គោលដៅ សមាជិកពេញសិទ្ធិ ឬសមាជិកគាំទ្រពុំមានលក្ខណៈសមស្របនឹងគោលដៅអង្គការ គសក ឬ ក៏អាចបង្កឱ្យមានផលលំបាកដល់កម្លាំងសមូហភាពនៃសមាជិកភាពអង្គការ គសក។

២) ការបោះឆ្នោតដោយសម្លេង ៥០%+១ ក្នុងចំណោមសមាជិកគណៈកម្មាធិការប្រតិបត្តិអនុម័តថាសាម៉ីអង្គការពុំអាចទទួលបានលក្ខខណ្ឌដូចចែងក្នុងគោលការណ៍ ៥.១ នៃប្រការ ៥ និងគោលការណ៍ជាបន្តបន្ទាប់នៃលក្ខន្តិកៈនេះ។

៥.៧.២ ក្នុងករណីដែលសមាជិកភាពត្រូវបញ្ឈប់ យោងតាមគោលការណ៍ការងារ ៥.៧.១ អង្គការ គសក ត្រូវដាក់សំណើដោយភ្ជាប់ជាមួយនូវមូលហេតុច្បាស់លាស់ ដើម្បីបញ្ឈប់សមាជិកភាព ជូនគណៈកម្មាធិការប្រតិបត្តិយ៉ាងហោចណាស់ដប់ប្រាំ (១៥)ថ្ងៃ មុនពេលប្រជុំសាមញ្ញរបស់ខ្លួន ដើម្បីផ្តល់លទ្ធភាព ពិនិត្យ និងដោះស្រាយ។

៥.៧.៣ ការមិនបង់កម្រៃសមាជិកភាពប្រចាំឆ្នាំផុតកំណត់ ៣ខែ នៃកាលបរិច្ឆេទដែលត្រូវបង់។ ក្នុងករណីនេះ ទាមទារឱ្យមានភស្តុតាងជាក់ស្តែងអំពីការរំលឹកពីរលើកអំពីការបង់កម្រៃនេះចំពោះ សមាជិកពេញសិទ្ធិ ឬ សមាជិកគាំទ្រមុននឹងបញ្ឈប់សមាជិកភាព។ ការផ្ញើលិខិតរំលឹកនេះ គឺជាភារកិច្ចនៃបុគ្គលិករបស់អង្គការ គសក។

៥.៧.៤ ការបញ្ឈប់សមាជិកភាពអនុលោមតាមប្រការ ៥.៧.២. សម្រេចឡើងដោយគណៈកម្មាធិការប្រតិបត្តិដោយលិខិតផ្ញើចេញពីការិយាល័យអង្គការ គសក។

៥.៧.៥ ការជូនដំណឹងជាលាយលក្ខ័អក្សរអំពីគោលបំណងសមាជិកពេញសិទ្ធិ ឬ សមាជិក ចូលរួមស្នើដកខ្លួនចេញពីសមាជិកភាព។

៥.៧.៦ ប្រសិនបើអង្គការសមាជិក ដកសមាជិកភាពរបស់ខ្លួន ដូចចែងក្នុង ៥.៧.២ នៃលក្ខន្តិកៈ គណៈកម្មាធិការប្រតិបត្តិមានភារកិច្ចបញ្ជាក់អំពីសមាជិកភាពនៃការដកនោះនៅក្នុងកិច្ចប្រជុំប្រចាំខែបន្ទាប់។

## ៥.៨ អំពីកិច្ចប្រជុំ

៥.៨.១ គណៈកម្មាធិការប្រតិបត្តិ តាមរយៈនាយក/នាយិកាប្រតិបត្តិត្រូវកោះប្រជុំសមាជិកភាពក្នុងរាល់ពីរ (២) ខែម្តង និងការប្រជុំវិសាមញ្ញនានា។

៥.៨.២ សន្និបាតប្រចាំឆ្នាំសម្រាប់សមាជិក គឺត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ ដើម្បីបូកសរុបការងារប្រចាំឆ្នាំដែលបានធ្វើកន្លងមក ហើយក៏ដើម្បីពិភាក្សាអំពីផែនការនានាសម្រាប់ឆ្នាំបន្ទាប់ផងដែរ។ សន្និបាតនេះ អាចរៀបចំធ្វើនៅថ្ងៃណាមួយដែលសមស្របសម្រាប់គណៈកម្មាធិការប្រតិបត្តិ ដោយមិនឱ្យហួសពីខែមិនានៃឆ្នាំបន្ទាប់។

៥.៨.៣ កិច្ចប្រជុំសាមញ្ញជាមួយអង្គការសមាជិក ត្រូវប្រារព្ធធ្វើយ៉ាងហោចណាស់រៀងរាល់ពីរ (២) ខែម្តង។ កាលបរិច្ឆេទនៃកិច្ចប្រជុំ គឺត្រូវកំណត់ដោយគណៈកម្មាធិការប្រតិបត្តិ ហើយត្រូវជូនជាដំណឹងដល់អង្គការសមាជិក។ តំណាងនៃអង្គការសមាជិកមានសិទ្ធិ បញ្ចេញមតិ ហើយបោះឆ្នោតជូសមុខឱ្យអង្គការដែលខ្លួនតំណាង ។ ភ្ញៀវ ឬភាគីដទៃអាចចូលរួមបាន លុះត្រាតែមានការឯកភាពជាមុនពីនាយក/នាយិកាប្រតិបត្តិ។

៥.៨.៤ កិច្ចប្រជុំពិសេស ដែលរួមមានតំណាង (ឬតំណាងច្រើននាក់) នៃអង្គការសមាជិក និងភ្ញៀវ ឬរួមមានតែតំណាងនៃអង្គការសមាជិក អាចកោះប្រជុំបានតាមរយៈ ៖

ក) ប្រធានដោយឆ្លងការពិភាក្សាជាមួយសមាជិកឯទៀតនៃគណៈកម្មាធិការប្រតិបត្តិ ឬ

ខ) តំណាងអង្គការសមាជិកស្នើជាលាយល័ក្ខអក្សរដល់ប្រធាននៃគណៈកម្មាធិការប្រតិបត្តិ ហើយដែលគាំទ្រ (ដោយហត្ថលេខា) ដោយសម្លេង ១ភាគ៥ (២០%) ពីសមាជិកទាំងអស់។ កិច្ចប្រជុំនឹងធ្វើឡើងក្នុងកំឡុងដប់ (១០) ថ្ងៃបន្ទាប់មក។

## ៥.៩ គូរ៉ុម (ចំនួនចាំបាច់ដើម្បីដំណើរការកិច្ចប្រជុំ)

៥.៩.១ រាល់ការប្រជុំដែលកោះហៅពីរសប្តាហ៍ជាមុនត្រូវមានវត្តមានចូលរួមយ៉ាងហោចណាស់ ១/៣ នៃអង្គការសមាជិក។

៥.៩.២ ចំនួនគូរ៉ុម អាចចាត់ទុកជាគ្រប់តាមរយៈ ការផ្តល់សិទ្ធិជំនួស។

៥.៩.៣ ចំនួនគូរ៉ុមចាំបាច់ព្រមជាមួយចំនួនអង្គការសមាជិកត្រូវប្រកាសនាពេលចាប់ផ្តើមកិច្ចប្រជុំនិមួយៗ។

## ៥.១០ ការផ្ទេរសិទ្ធិជំនួស (PROXIES)

៥.១០.១ ការផ្ទេរសិទ្ធិជំនួស គឺត្រូវធ្វើជាលាយលក្ខ័អក្សរ។ ការណ៍នេះ អាចធ្វើបាន គឺដោយអង្គការសមាជិកមួយផ្ទេរសិទ្ធិទៅឱ្យសមាជិកពេញសិទ្ធិ ឬសមាជិកគាំទ្រធ្វើការបោះឆ្នោតជំនួសខ្លួន។

៥.១០.២ អង្គការសមាជិកអាចបោះឆ្នោត ដោយការផ្ទេរសិទ្ធិ

៥.១០.៣ សមាជិកពេញសិទ្ធិ ឬសមាជិកគាំទ្រអាចប្រើសម្លេងនៃការផ្ទេរសិទ្ធិ តែមួយដងគត់ក្នុងករណីនិមួយៗ។

## ៥.១១ អំពីការបោះឆ្នោត

៥.១១.១ ប្រធានកិច្ចប្រជុំទទួលបន្ទុក បង្កលក្ខណៈធ្វើយ៉ាងណាឱ្យសមាជិកចូលរួមប្រជុំ គ្រប់ចំនួនហើយប្រកាសជូនកិច្ចប្រជុំ។ ជាមួយគ្នាដែរ គឺត្រូវពិនិត្យថាសម្លេងផ្ទេរសិទ្ធិទាំងអស់ បានធ្វើឡើងដោយត្រឹមត្រូវជាលាយលក្ខ័អក្សរពិតប្រាកដមែនហើយ ត្រូវធ្វើយ៉ាងណាឱ្យសមាជិកអង្គការនោះបោះឆ្នោតបានតែមួយសម្លេងក្នុងករណីនិមួយៗ។

៥.១១.២ រាល់ករណីដែលទាមទារការសម្រេចតាមសន្លឹកឆ្នោត ត្រូវផ្តួចផ្តើមលើកឡើងដោយតំណាងនៃអង្គការសមាជិកមួយរួចហើយសំណើនេះគាំទ្រដោយតំណាងអង្គការសមាជិកមួយទៀត។

៥.១១.៣ សំណើទាំងអស់ដែលត្រូវឆ្លងកាត់ការបោះឆ្នោតចាំបាច់ត្រូវកត់ត្រាឱ្យបានច្បាស់លាស់មុននឹងធ្វើការបោះឆ្នោត។

៥.១១.៤ ការបោះឆ្នោតជ្រើសរើសសមាសភាពសមាជិកភាព អំពីកិច្ចការហិរញ្ញវត្ថុ និងសមាសភាពគណៈកម្មាធិការផ្សេងៗ គឺត្រូវធ្វើដោយសម្ងាត់ និងលាយលក្ខ័អក្សរ។ ការកត់ត្រាអំពីសមាសភាពអ្នកបោះឆ្នោត គឺជាការចាំបាច់។

៥.១១.៥ ចំពោះការបោះឆ្នោតលើករណីផ្សេងទៀត គឺត្រូវធ្វើដោយលើកដៃលើកលែងតែមានការបោះឆ្នោត សម្រេចឱ្យធ្វើតាមទម្រង់ផ្សេងទៀត។

៥.១១.៦ ប្រធានកិច្ចប្រជុំ ទទួលខុសត្រូវពិភាក្សា និង កំណត់ទម្រង់បោះឆ្នោតយោងតាមបែបបទចែងក្នុងលក្ខន្តិកៈ និងគោលការណ៍របស់ គសក ។ សមាជិកទាំងឡាយបោះឆ្នោត ស្នើប្រើទម្រង់ក្នុងការបោះឆ្នោត។

៥.១១.៧ រាល់បញ្ហាគោលការណ៍ ដែលឆ្លងកាត់ការបោះឆ្នោត ត្រូវផ្សព្វផ្សាយជាលាយលក្ខ័អក្សរយ៉ាងហោចណាស់១០ថ្ងៃ មុនថ្ងៃកំណត់បោះឆ្នោត។ ក៏ប៉ុន្តែសមាជិកអាចលើកបញ្ហាលើការបោះឆ្នោតសម្រេចនៅពេលកិច្ចប្រជុំ ហើយធ្វើការបោះឆ្នោតតែម្តងក្នុងពេលប្រជុំនោះ។

៥.១១.៨ សម្លេងឆ្នោតដែលអាចចាត់ទុកថាការអនុម័ត ÷

៥.១១.៨.១ ដើម្បីបញ្ចូលជាសមាជិក គសក ឬដើម្បីអនុម័ត គម្រោងថវិកាទាមទារសម្លេងឆ្នោតភាគច្រើន (៥០%+១) នៃសមាជិកភាពទាំងមូល។

៥.១១.៨.២ ដើម្បីកែប្រែលក្ខន្តិកៈ កែប្រែគោលការណ៍ និងដើម្បីជ្រើសរើស/ដកចេញសមាជិកគណៈកម្មាធិការប្រតិបត្តិ គឺទាមទារសម្លេងភាគច្រើន (៥០%+១) នៃអង្គការសមាជិកទាំងអស់។

៥.១១.៨.៣ ចំពោះការបោះឆ្នោតរើសសមាសភាពគណៈកម្មាធិការនានា ក្រៅពីគណៈកម្មាធិការប្រតិបត្តិ និងចំពោះករណីផ្សេងៗទៀតដែលត្រូវឆ្លងកាត់ការបោះឆ្នោត គឺទាមទារសម្លេង ៥០%+១នៃចំនួនសមាជិកដែលមានវត្តមាន និងសម្លេងផ្ទេរសិទ្ធិផងដែរ។

៥.១១.៩ ក្នុងករណីដែលចាំបាច់ហើយជាបន្ទាន់ដែលអង្គការ គសក ត្រូវការសេចក្តីសម្រេចក៏ប៉ុន្តែ ពុំមានគូរ៉ុមក្នុងកិច្ចប្រជុំការបោះឆ្នោតអាចប្រព្រឹត្តទៅបានក្នុងចំណោមសមាជិកដែលមានវត្តមានហើយលទ្ធផលជាស្ថាពរ គឺអាចទទួលបានតាមរយៈការស្នើឱ្យបោះឆ្នោតតាមប្រៃសណីយ៍ ឬសាអេឡិចត្រូនិចចំពោះសមាជិកដែលពុំមានវត្តមានមកចូលរួមប្រជុំ។

៥.១១.១០ រាល់សេចក្តីសម្រេចតាមសន្លឹកឆ្នោតដោយអង្គការ គសក គឺពុំមានអានុភាពលើអង្គការសមាជិកទេ ក៏ប៉ុន្តែគណៈកម្មាធិការប្រតិបត្តិ និងបុគ្គលិកអង្គការ គសក គឺចាំបាច់ត្រូវ អនុលោមតាមអ្វីដែលបានសម្រេច។

# ប្រការ ៦: គណៈកម្មាធិការប្រតិបត្តិ

## ៦.១ តួនាទីរបស់គណៈកម្មាធិការប្រតិបត្តិ

គណៈកម្មាធិការប្រតិបត្តិ ដើរតួនាទីជាក្រុមប្រឹក្សានាយកនៃអង្គការ គសក គណៈកម្មាធិការមានកិច្ចការចំបងដើម្បីណែនាំ និងផ្តល់យោបល់ដល់នាយក/នាយិកាប្រតិបត្តិទៅលើការអភិវឌ្ឍគោលការណ៍ដែលសមាជិកអង្គការ គសក ចង់បាន។ គណៈកម្មាធិការប្រតិបត្តិ មានការទទួលខុសត្រូវចំពោះសមាជិកភាពអង្គការ គសក គ្រប់ពេលវេលា។ គណៈកម្មាធិការបង្កើតគ្រោងទូលំទូលាយមួយសម្រាប់គោលការណ៍នានារបស់អង្គការ គសក ដែលត្រូវទទួលការយល់ស្របពីសមាជិកភាពនៃអង្គការ គសក។ គណៈកម្មាធិការប្រតិបត្តិជួយដល់នាយក/នាយិកាប្រតិបត្តិក្នុងការបកស្រាយអាណត្តិរបស់ខ្លួន និងបញ្ជាក់ថារាល់សកម្មភាពទាំងអស់ដែល អនុវត្តក្នុងនាមសមាជិកអង្គការ គសក ដោយនាយក/នាយិកាប្រតិបត្តិឬសមាជិកនៃគណៈកម្មាធិការប្រតិបត្តិ ឬក៏បុគ្គលិកនៃអង្គការ គសក ស្ថិតនៅក្នុងអាណត្តិផ្តល់ឱ្យដោយអង្គការជាសមាជិក ព្រមទាំងប្រព្រឹត្តតាមគោលការណ៍ដែលបានឯកភាពទូទៅ។

## ៦.២ ភារកិច្ចផ្សេងៗ នៃគណៈកម្មាធិការប្រតិបត្តិ

៦.២.១ គណៈកម្មាធិការប្រតិបត្តិនឹងធានានូវការគ្រប់គ្រងទូទៅឱ្យមានប្រសិទ្ធភាព និងការទទួលខុសត្រូវរបស់អង្គការ គសក ចំពោះសមាជិកភាព និងដៃគូរបស់ខ្លួនក្នុងរង្វង់ច្បាប់នៃប្រទេសកម្ពុជា ។

៦.២.២ គណៈកម្មាធិការប្រតិបត្តិនឹងរៀបចំគោលការណ៍ដោយមានការយល់ព្រមពីសមាជិកភាព និងជ្រើសយកសកម្មភាពដើម្បីឆ្លើយតបទៅនឹងរឿងហេតុផ្សេងៗដែលលើកឡើងដោយសមាជិកភាព។

៦.២.៣ គណៈកម្មាធិការប្រតិបត្តិនឹងជ្រើសរើសយក និងអនុវត្តកិច្ចព្រមព្រៀងជាមួយនឹងនាយក/នាយិកាប្រតិបត្តិ។ គណៈកម្មាធិការប្រតិបត្តិនឹងត្រួតពិនិត្យរាល់កិច្ចការទាំងអស់ដែលបានរៀបចំជាពិសេសសម្រាប់នាយក/នាយិកាប្រតិបត្តិ ហើយជាកិច្ចការដែលនាយក/នាយិកាប្រតិបត្តិនឹងធានាខុសត្រូវជាដំបូង។

៦.២.៤ គណៈកម្មាធិការប្រតិបត្តិ នឹងពិគ្រោះ ពិនិត្យ និងយល់ព្រមមុន និងបញ្ជូនចែក ឬប្រកាស ជាផ្លូវការនូវឯកសារទាំងអស់ដែលបានព្រាងដោយនាយកប្រតិបត្តិ ដូចបានរាយនាមក្នុងបញ្ជីនៃប្រការ ៨ ។

៦.២.៥ សំណូមពរឱ្យមានការសម្រេចនៃអង្គការ គសក ដោយសមាជិកនានាឬ នាយក/នាយិកាប្រតិបត្តិហួសពីការប្រតិបត្តិធម្មតារបស់ការិយាល័យ គសក នឹងត្រូវបានរៀបចំតាមអាទិភាពដោយគណៈកម្មាធិការប្រតិបត្តិ។

៦.២.៦ គ្មានសមាជិកណាមួយ នៃគណៈកម្មាការប្រតិបត្តិ បុគ្គលិក ឬសមាជិកភាពនៃអង្គការ គសក អាចបង្ហាញខ្លួនទោះជាក្នុងការសរសេរ ឬក៏បញ្ចេញមុខជាអ្នកនាំពាក្យជាផ្លូវការនៃអង្គការ គសក ដោយពុំមានការតែងតាំងពីនាយក/នាយកប្រតិបត្តិ ឬ ប្រធាននៃគណៈកម្មាធិការប្រតិបត្តិនៃអង្គការ គសក ដើម្បីទៅបកស្រាយក្នុងនាមអង្គការ គសក អំពីបញ្ហាអ្វីមួយ។ អាជ្ញាធរដែលផ្តល់នូវការទទួលខុសត្រូវនេះត្រូវតែអនុវត្តតាមគោលការណ៍សម្រាប់ការ ទំនាក់ទំនងព័ត៌មានជាផ្លូវការ ដូចមានចែងក្នុងប្រការ ៨ ខាងក្រោម។

៦.២.៧ គណៈកម្មាធិការប្រតិបត្តិ នឹងធានានូវការរៀបចំកិច្ចប្រជុំសាមញ្ញប្រចាំឆ្នាំដែលក្នុងពេលនោះរបាយការណ៍ប្រចាំឆ្នាំ និងការត្រួតពិនិត្យហិរញ្ញកិច្ចប្រចាំឆ្នាំ និងត្រូវយកមកបកស្រាយ។

៦.២.៨ គណៈកម្មាធិការប្រតិបត្តិ និងបង្កើត និងរំសាយគណៈកម្មការនានា តាមសេចក្តីត្រូវការដើម្បីបំពេញនូវគោលដៅទាំងឡាយរបស់អង្គការ គសក ដូចបានចែងក្នុងប្រការ ៧។

៦.២.៩ គណៈកម្មាធិការប្រតិបត្តិនឹងរៀបចំកម្មវិធីប្រជុំមួយ និងជួបប្រជុំគ្នាយ៉ាងតិច ៤ដងក្នុង១ឆ្នាំ។ គណៈកម្មាធិការប្រតិបត្តិនឹងអាចធ្វើការប្រជុំពិសេសៗទៅតាមកាលៈទេសៈដែលត្រូវការចាំបាច់។

៦.២.១០ គណៈកម្មាធិការប្រតិបត្តិការនឹងតាមដានពិនិត្យកិច្ចការហិរញ្ញវត្ថុនៃអង្គការ គសក ដែលបានអនុវត្តដោយបុគ្គលិក និងទទួលខុសត្រូវក្នុងការចុះហត្ថលេខានៅលើ របាយការណ៍ហិរញ្ញវត្ថុទាំងឡាយក្រោយពីការយល់ព្រមពីគណៈកម្មាធិការប្រតិបត្តិ។

៦.២.១១ គណៈកម្មាធិការប្រតិបត្តិនឹងទទួលធានាខុសត្រូវនូវកិច្ចការសម្រេចបាន និងធានារ៉ាប់រងផ្នែកហិរញ្ញវត្ថុរបស់អង្គការ គសក ហើយគណៈកម្មាធិការប្រតិបត្តិនឹងអាចមានសិទ្ធិ ចុះហត្ថលេខាទៅលើកិច្ចការហិរញ្ញវត្ថុផ្សេងៗក្នុងវង្វង់កំណត់អនុញ្ញាតិដោយគណៈកម្មាធិការប្រតិបត្តិរៀងរាល់ឆ្នាំក្នុងការប្រជុំលើកដំបូងនៃគណៈកម្មាធិការប្រតិបត្តិបន្ទាប់ពីកិច្ចប្រជុំវិសាមញ្ញប្រចាំឆ្នាំចប់ភ្លាម។

## ៦.៣ កាតព្វកិច្ចផ្សេងៗរបស់សមាជិក នៃគណៈកម្មាធិការប្រតិបត្តិ

៦.៣.១ ប្រធាន ឬក៏អនុប្រធានក្នុងការអវត្តមានរបស់ប្រធាន នឹងធ្វើជាប្រធានកិច្ចប្រជុំផ្សេងៗទៀតរបស់អង្គការ គសក ឬក៏កិច្ចប្រជុំផ្សេងៗនៃគណៈកម្មាធិការប្រតិបត្តិ ។

៦.៣.២ ប្រធាននឹងទទួលខុសត្រូវរ៉ាប់រងក្នុងការអនុញ្ញាតបញ្ចេញនូវកំណត់ហេតុរបាយការណ៍ និងរាល់ឯកសារទាំងអស់ដែលជាកម្មសិទ្ធិរបស់អង្គការ គសក តាមការយល់ព្រមពីគណៈកម្មាធិការប្រតិបត្តិ។

៦.៣.៣ អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការប្រតិបត្តិនឹងអាចទទួលការបែងចែកការទទួលខុសត្រូវផ្សេងៗយោងទៅលើកិច្ចការងារសំខាន់ៗដូចតទៅ ៖

១) ហិរញ្ញវត្ថុ នឹងរកមូលនិធិ

២) សមាជិកភាព

៣) គ្រប់គ្រងបុគ្គលិក និង រកបុគ្គលិកមកកាន់ការងារ

៤) កិច្ចការផ្សេងៗទៀត ដែលអាចត្រូវប្រគល់ឱ្យម្តងម្កាល ។

## ៦.៤ នីតិវិធីនៃការបោះឆ្នោត សម្រាប់គណៈកម្មាធិការប្រតិបត្តិ

៦.៤.១ អង្គការសមាជិកភាពនៃអង្គការ គសក ធ្វើការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការ-ប្រតិបត្តិ ចំនួន០៧រូប សម្រាប់អាណត្តិ ២ឆ្នាំ។ បន្ទាប់ពីការបោះឆ្នោតមកសមាជិកគណៈកម្មាធិការ-ប្រតិបត្តិ ត្រូវរៀបចំកិច្ចប្រជុំវិសាមញ្ញមួយ ដើម្បីបោះឆ្នោតជ្រើសរើស និងតែងតាំងប្រធាន អនុប្រធាន ហិរញ្ញឹក និង សមាជិក នៅក្នុងការប្រជុំលើកដំបូងរបស់ខ្លួន។ នាយក/នាយិកាប្រតិបត្តិអង្គការ គសក មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំជាមួយសមាជិកគណៈកម្មាធិការប្រតិបត្តិ ប៉ុន្តែគ្មានសិទ្ធិបោះឆ្នោត និងគ្មានសិទ្ធិសម្រេច ។

៦.៤.២ ការបោះឆ្នោតគណៈកម្មាធិការប្រតិបត្តិ ត្រូវធ្វើឡើងម្តងក្នុងមួយឆ្នាំ ដើម្បីជ្រើសរើសសមាជិកថ្មីជំនួសឱ្យសមាជិកដែលបានអស់អណត្តិ តាមរយៈកិច្ចប្រជុំសមាជិក ឬ តាមរយៈសារអេឡិត្រូនិច ហើយលទ្ធផលនៃការបោះឆ្នោត ត្រូវប្រកាសជាសាធារណៈនៅក្នុងសន្និបាតប្រចាំឆ្នាំសម្រាប់សមាជិក។

៦.៤.៣ ក្នុងករណីសមាជិកគណៈកម្មាធិការប្រតិបត្តិស្នើលាឈប់លើសពី០៣ខែ មុនពេលចប់អាណត្តិ គឺចាំបាច់ត្រូវមានការបោះឆ្នោតរើសសមាជិកជំនួសសម្រាប់បន្តអាណត្តិ។

៦.៤.៤ គណៈកម្មាធិការប្រតិបត្តិ ត្រូវគោរពនូវរាល់ការសម្រេចចិត្ត ដែលអនុម័តដោយអង្គការសមាជិក។

៦.៤.៥ បេក្ខជនជាបុគ្គលិកមកពីអង្គការសមាជិកអាចជ្រើសរើសឱ្យឈរឈ្មោះ ចំពោះបុគ្គលិកដែលមានលទ្ធភាពដើម្បីបម្រើការងារក្នុងគណៈកម្មាធិការប្រតិបត្តិ។ បេក្ខភាពជាស្ត្រី ត្រូវបានលើកទឹកចិត្តក្នុងការចូលរួមឈរឈ្មោះ ដើម្បីជ្រើសរើសជាសមាជិកគណៈកម្មាធិការប្រត្តិបត្តិរបស់អង្គការ គសក ។

៦.៤.៦ លិខិតបំពេញសម្រាប់ឈរឈ្មោះនឹងត្រូវផ្តល់ឱ្យ ហើយត្រូវតែបំពេញដើម្បីឱ្យការឈរឈ្មោះមានប្រសិទ្ធភាព ដោយមានការឯកភាពផងដែរពីបុគ្គលដែលត្រូវគេជ្រើសរើសឱ្យឈរឈ្មោះ។

៦.៤.៧ ការឈរឈ្មោះទាំងនេះ នឹងត្រូវទទួលយកក្នុងកំឡុងពេលយ៉ាងតិចបំផុត ៤សប្តាហ៍ មុនការបោះឆ្នោត ហើយឈ្មោះនៃបុគ្គលឈរឈ្មោះទាំងឡាយនឹងត្រូវបិទប្រកាសនៅឯការិយាល័យ ឬដាក់

បង្ហាញនៅលើគេហទំព័ររបស់អង្គការ គសក ក្នុងខណៈពេលដែលបានទទួល ។

៦.៤.៨ កាលបរិច្ឆេទបញ្ចប់នៃការជ្រើសរើសឱ្យឈរឈ្មោះ និងត្រូវកំណត់ពេល ២ សប្តាហ៍មុនការបោះឆ្នោត ។

៦.៤.៩ បញ្ជីនៃអ្នកឈរឈ្មោះទាំងអស់នឹងត្រូវបញ្ជូនចែកទៅឱ្យសមាជិកពេញសិទ្ធិទាំងឡាយដោយផ្ទាល់ ឬផ្ញើរតាមសារអេឡិចត្រូនិច (អ៊ីមែល) ក្នុងរយៈពេល ១០ថ្ងៃ មុនការបោះឆ្នោត ។

៦.៤.១០ ការបោះឆ្នោតរើសសមាជិកគណៈកម្មាធិការប្រតិបត្តិនឹងត្រូវរៀបចំធ្វើឡើង១ដងជាប្រចាំឆ្នាំ។ សមាជិកនិមួយៗនៃគណៈកម្មាធិការប្រតិបត្តិនឹងត្រូវបម្រើការងាររយៈពេល២ឆ្នាំក្នុងមួយអាណត្តិ ប៉ុន្តែគ្មានសមាជិកណាមួយនឹងអាចបម្រើការងារលើសពី ២អាណត្តិបន្តបន្ទាប់គ្នាឡើយ ។

## ៦.៥ បែបបទការងារ

៦.៥.១ នៅពេលប្រជុំលើកដំបូង បន្ទាប់ពីកិច្ចប្រជុំវិសាមញ្ញប្រចាំឆ្នាំគណៈកម្មាធិការប្រតិបត្តិ នឹងឯកភាពទៅលើទម្រង់ការប្រតិបត្តិសម្រាប់ការប្រជុំផ្សេងៗរបស់ខ្លួនដែលសមស្របទៅតាមគោលការណ៍លក្ខន្តិកៈនៃអង្គការ គសក។

៦.៥.២ កាលវិភាគសម្រាប់កិច្ចប្រជុំទាំងអស់នៃគណៈកម្មាធិការប្រតិបត្តិ នឹងត្រូវបិទប្រកាសនៅអង្គការ គសក ។

៦.៥.៣ អង្គការជាសមាជិកអាចធ្វើសំណូមពរគ្រប់ពេលវេលាជួបជាមួយគណៈកម្មាធិការប្រតិបត្តិដើម្បីពិគ្រោះអំពីកិច្ចការសំខាន់ៗ ។

៦.៥.៤ ដើម្បីឱ្យមានការសម្រេចចិត្តណាមួយដោយគណៈកម្មាធិការប្រតិបត្តិ សមាជិកពេញសិទ្ធិភាគច្រើននៃគណៈកម្មាធិការត្រូវមានវត្តមានហើយយ៉ាងតិចណាស់ក៏ចំនួនភាគច្រើននៃអ្នកដែលមាន វត្តមានត្រូវមានការឯកភាពនឹងគ្នា។

៦.៥.៥ ការសម្រេចចិត្តជាសាមញ្ញផ្សេងៗនឹងត្រូវធ្វើឡើងដោយគណៈកម្មាធិការប្រតិបត្តិក្នុងពេលប្រជុំ មិនមែនតាមរយៈការពិគ្រោះដោយខ្លួនទេ។ ធ្វើដូច្នេះគឺដើម្បីជំរុញឱ្យមានការពិភាក្សាគ្នាការដឹងឮនូវទស្សនៈផ្សេងៗពីគ្នាការអនុវត្តប្រកបដោយជំនាញខ្ពស់នូវកិច្ចធុរៈរបស់អង្គការ គសក និងការទទួលខុសត្រូវនៃសមាជិកពេញសិទ្ធិរបស់គណៈកម្មាធិការក្នុងការចូលរួមកិច្ចប្រជុំនានា ។

៦.៥.៦ ចំពោះកិច្ចការផ្សេងៗទាក់ទងនឹងបុគ្គលិក ឬការពាក់ព័ន្ធដទៃទៀតដែលពិបាកដោះស្រាយ គណៈកម្មាធិការប្រតិបត្តិ អាចជ្រើសយកការប្រជុំមិនចំហរមួយ។

## ៦.៦ កំណត់ហេតុនៃកិច្ចប្រជុំ និង វត្តមាន

៦.៦.១ កំណត់ហេតុផ្សេងៗ រួមទាំងការចូលរួមនៃកិច្ចប្រជុំទាំងអស់នៃគណៈកម្មាធិការប្រតិបត្តិ នឹងត្រូវរក្សាទុកដោយនាយក/នាយិកាប្រតិបត្តិ ឬសមាជិកចាត់តាំងម្នាក់នៃគណៈកម្មាធិការប្រតិបត្តិក្នុងករណី ដែលមានសម័យប្រជុំដោយមិនចំហរមួយ នៅពេលដែលនាយក/នាយិកាប្រតិបត្តិមានការ

អវត្តមាន ។

៦.៦.២ កំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិទាំងឡាយត្រូវមានជាប្រចាំ ដើម្បីឱ្យសមាជិកភាពធ្វើការត្រួតពិនិត្យ ប៉ុន្តែកំណត់ហេតុនៃសម័យប្រជុំដោយមិនចំហរមិនអាចផ្តល់អោយសមាជិកភាពបានទេ បើសិនជាគ្មានការអនុញ្ញាតិច្បាស់លាស់តាមរយៈការបោះឆ្នោតមួយជាឯកច្ឆ័ននៃគណៈកម្មាធិការប្រតិបត្តិ ។

៦.៦.៣ ក្នុងភារកិច្ចអនុវត្តការមិនលាក់បាំង និងភាពជាចំហរសមាជិកពេញសិទ្ធិទាំងឡាយនៃគណៈកម្មាធិការប្រតិបត្តិ នឹងគោរពនូវអ្វីដែលចាត់ទុកថាមិនអាចផ្សព្វផ្សាយបានជាចាំបាច់ដើម្បីរក្សានូវភាពសុចរិតនៃអង្គការ គសក សន្តិសុខនៃបុគ្គលម្នាក់ៗ និងផលប្រយោជន៍ផ្សេងៗ នៃអង្គការជាសមាជិករបស់ គសក ។

## ៦.៧ ការរំសាយនៃគណៈកម្មាធិការប្រតិបត្តិ

៦.៧.១ គណៈកម្មាធិការប្រតិបត្តិទាំងមូលអាចតែងតាំង ឬរំសាយដោយយោងតាមលក្ខណៈខាងក្រោម ÷

៦.៧.១.១ ការសម្រេចចិត្តមួយធ្វើឡើងដោយចំនួន ៥០% បូក ១ នៃសមាជិកទាំងអស់អាចរំសាយគណៈកម្មាធិការប្រតិបត្តិ និងរៀបចំការបោះឆ្នោតជាថ្មី ។

៦.៧.២ សមាជិកនិមួយៗនៃគណៈកម្មាធិការប្រតិបត្តិអាចរំសាយដោយយោងតាមលក្ខណៈខាងក្រោម៖

៦.៧.២.១ ការចប់អាណត្តិនៃរយៈពេលកាន់តំណែងការងារ ។

៦.៧.២.២ ការសម្រេចចិត្តមួយធ្វើឡើងដោយចំនួន ៥០% បូក ១ នៃសមាជិកទាំងអស់ដើម្បីរំសាយសមាជិកណាម្នាក់

៦.៧.២.៣ សមាជិកនៃគណៈកម្មាធិការប្រតិបត្តិដែលត្រូវបញ្ឈប់ជាបុគ្គលិកសមាជិកនៃអង្គការសមាជិកណាមួយរបស់ គសក ដោយសារអង្គការនោះបញ្ឈប់ជាសមាជិកភាពក្នុងអង្គការ គសក ឬក៏សមាជិកបុគ្គលិកនោះចាកចេញពីការងារនៃអង្គការជាសមាជិក ។ សមាជិកបុគ្គលិកនោះអាចមានសិទ្ធិឈរឈ្មោះបោះឆ្នោតម្តងទៀត និងបម្រើការងារក្នុងគណៈកម្មាធិការប្រតិបត្តិបើសិនជាមានការងារធ្វើនៅអង្គការជាសមាជិកមួយទៀត ។

៦.៧.២.៤ ក្នុងករណីសមាជិកគណៈកម្មាធិការប្រតិបត្តិណាម្នាក់មានការអវត្តមាន ឬមិនបានចូលរួមការប្រជុំគណៈកម្មាធិការប្រតិបត្តិបី (៣) ដងជាប់ៗគ្នាអាចនឹងមានសំណើឱ្យលាលែងពីសមាជិក គណៈកម្មាធិការ ។

# ប្រការ ៧: គណៈកម្មការនានា

## ៧.១ ការតែងតាំងគណៈកម្មការនានា ( ក្រៅពីគណៈកម្មាធិការប្រតិបត្តិ)

៧.១.១ គណៈកម្មាធិការប្រតិបត្តិអាចបង្កើតនូវគណៈកម្មការ និង គណៈកម្មការពិសេសបើសិនជាបានយល់ឃើញថាជាការត្រឹមត្រូវ ឬក៏បានទទួលសំណូមពរពីសមាជិកពេញសិទ្ធិទាំងឡាយ ។

៧.១.១.១ គោលបំណងនៃគណៈកម្មការនានាគឺផ្តល់ជាជំនួយដល់គណៈកម្មាធិការប្រតិបត្តិ ក្នុងកិច្ចការផ្សេងៗ ដូចជាស្ថានភាពហិរញ្ញវត្ថុ និងសមាជិកភាព។ គណៈកម្មការពិសេសនឹងត្រូវបង្កើតឡើងដើម្បីអនុវត្តកិច្ចការចាំបាច់ផ្សេងៗ ផងដែរ ដើម្បីជាជំនួយការដល់សមាជិកនៃអង្គការ គសក ក្នុងការដោះស្រាយបញ្ហាទាំងឡាយដែលជាផលប្រយោជន៍នៃសមាជិកទាំងអស់ ។

៧.១.១.២ រយៈពេលបម្រើការងារនៃគណៈកម្មការទាំងនេះ នឹងអាស្រ័យទៅលើប្រភេទនៃកិច្ចការរបស់ គណៈកម្មការ ហើយដែលនឹងត្រូវកំណត់នៅពេលដែលបានជ្រើសតាំង ។

៧.១.២ សមាជិកនៃគណៈកម្មការបែបនេះ នឹងត្រូវទទួលតំណែងផ្តល់ឱ្យដោយគណៈកម្មាធិការប្រតិបត្តិ ក្រោយពីសមាជិកទាំងនោះបានទទួលយល់ព្រមពីសមាជិកពេញសិទ្ធិទាំងឡាយក្នុងសម័យប្រជុំទៀងទាត់មួយដោយមានចំនួនត្រូវការចាំបាច់ ៥០ +១ ។

៧.១.៣ លក្ខណៈអនុវត្តការងារសម្រាប់គណៈកម្មការទាំងអស់នឹងត្រូវបង្កើតឡើងដោយគណៈកម្មាធិការប្រតិបត្តិ ។

## ៧.២ សិទ្ធិចូលរួមនៅក្នុងគណៈកម្មការនានា

៧.២.១ សមាជិកពេញសិទ្ធិ នៃគណៈកម្មការដែលត្រូវអាចជ្រើសយកបានក្នុងចំណោមបុគ្គលិកនៃអង្គការជាសមាជិកពេញសិទ្ធិ ឬក៏អង្គការជាសមាជិកគាំទ្រ និងអង្គការដៃគូ។

៧.២.២ គ្រប់អង្គការជាសមាជិកអាចជ្រើសរើសបុគ្គលដែលមានសិទ្ធិឱ្យឈរឈ្មោះដើម្បីបម្រើការងារ ក្នុងគណៈកម្មការផ្សេងៗរបស់អង្គការ គសក ។

៧.២.៣ អ្នកតំណាងនៃអង្គការនានាដែលមិនមែនជាសមាជិកភាពនៃ គសក អាចត្រូវបានអញ្ជើញចូលរួមជាសមាជិកគណៈកម្មាធិការនានាបើសិនជាចាំបាច់។

៧.២.៤ អនុគណៈកម្មការនិមួយៗត្រូវមានសមាជិកចាត់តាំងម្នាក់ក្នុងគណៈកម្មាធិការប្រតិបត្តិ ។

៧.២.៤.១ បើសិនជាសមាជិកចាត់តាំងដោយគ្មាន សម្លេងឆ្នោតក្នុងអនុគណៈកម្មការមានការអវត្តមានក្នុងសម័យប្រជុំមួយ គណៈកម្មាធិការប្រតិបត្តិនឹងខិតខំគ្រប់លទ្ធភាពដើម្បីរកសមាជិកពេញសិទ្ធិរបស់ខ្លួនម្នាក់ទៀតឱ្យមកបម្រើកិច្ចការតាមរយៈការផ្ទេរសិទ្ធិរបស់បុគ្គលដែលអវត្តមាន ។

៧.២.៤.២ បើសិនជាអនុគណៈកម្មការមួយនៅសេសសល់សមាជិកពេញសិទ្ធិតិចជាង ៣រូប ហើយនៅសេសសល់ជាង ២ខែទៀតនៃរយៈពេលកាន់តំណែងរបស់ពួកគេគណៈកម្មាធិការប្រតិបត្តិ និងចាត់តាំងសមាជិកថ្មីឱ្យមកបំពេញកន្លែងដែលបាត់បង់សមាជិក ។

៧.២.៥ ប្រធាននៃគណៈកម្មការនិមួយៗ នឹងត្រូវបានបោះឆ្នោតជ្រើសរើសដោយសមាជិកពេញសិទ្ធិ នៃគណៈកម្មការហើយសមាជិកពេញសិទ្ធិនៃគណៈកម្មការអាចត្រូវបានចាត់តាំងឱ្យឈរឈ្មោះកាន់តំណែងជាប្រធាន ។

## ប្រការ ៨: នាយកប្រតិបត្តិ នៃអង្គការ គសក

៨.១ នាយក/នាយិកាប្រតិបត្តិគ្មានសិទ្ធិបោះឆ្នោត ហើយជាសមាជិកក្រៅផ្លូវការនៃគណៈកម្មាធិការប្រតិបត្តិ។ នាយក/នាយិកាប្រតិបត្តិ នឹងត្រូវជ្រើសរើសមនុស្សដែលមានសមត្ថភាពសមរម្យសម្រាប់បំពេញការងារដំបូង ដែលមានរយៈពេល៤ឆ្នាំក្នុងមួយអាណត្តិ។ នាយក/នាយិកាប្រតិបត្តិអាចបន្តការងារបានមួយ (១)អាណត្តិទៀត ប្រសិនបើមានការពេញចិត្តដោយសម្លេងភាគច្រើន ៥០% + ១ នៃសមាជិកគណៈកម្មាធិការប្រតិបត្តិ និងបុគ្គលិកអង្គការ គសក អំពីការបំពេញការងារ និងស្នាដៃរបស់នាយក/នាយិកាប្រតិបត្តិនោះ។

៨.២ នាយក/នាយិកាប្រតិបត្តិ គឺបម្រើគណៈកម្មាធិការប្រតិបត្តិជាលេខាធិការ។ បុគ្គលនេះមានតួនាទីរៀបចំអង្គប្រជុំនៃគណៈកម្មាធិការប្រតិបត្តិដោយរាប់ទាំងការរៀបចំរបៀបវារៈ។ នាយក/នាយិកាប្រតិបត្តិ នឹងស្នើយោបល់គណៈកម្មាធិការប្រតិបត្តិ ចំពោះរាល់បណ្តាគោលការណ៍ ដែលពាក់ព័ន្ធនឹងទំនាក់ទំនងរវាងអង្គការ គសក និងសមាជិកទាំងអស់ ។ បុគ្គលរូបនេះ គឺត្រូវព្យាយាមធ្វើយ៉ាងណាឱ្យការិយាល័យអង្គការ គសក អនុវត្តយ៉ាងសមស្រប នូវរាល់ការសម្រេច និងគម្រោងផែនការដែលអនុម័តដោយគណៈកម្មាធិការប្រតិបត្តិ ។ បុគ្គលរូបនេះ គឺត្រូវសហការហើយប្រឹក្សាយ៉ាងជិតស្និទ្ធជាមួយអនុប្រធាន អង្គការ គសក ។

៨.៣ ភារកិច្ចដទៃទៀត នៃនាយក/នាយិកាប្រតិបត្តិនិងការទទួលខុសត្រូវគឺចែងដូចខាងក្រោមនេះ ÷

១) រៀបចំសំណើរអែង្គាសថវិកានានា ដើម្បីដាក់ជូនគណៈកម្មាធិការប្រតិបត្តិដើម្បីឆ្លង ការឯកភាពអំពីសំណើទាំងនោះ ។

២) បង្កលក្ខណៈឱ្យមានការចុះត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុប្រចាំឆ្នាំនៅអង្គការ គសក ។

៣) រៀបចំកាលវិភាគ នៃពិធីនានា និង ផែនការការងារប្រចាំឆ្នាំ សម្រាប់អង្គការ គសក ។

៤) លើករបៀបវារៈ នៃរាល់កិច្ចប្រជុំនៃអង្គការ គសក ដើម្បីឆ្លងការឯកភាពពី គណៈកម្មាធិការប្រតិបត្តិ ។

៥) បើសិនជាមានការឯកភាពពីគណៈកម្មាធិការប្រតិបត្តិ នាយក/នាយិកាប្រតិបត្តិអាចបំពេញតួនាទីជាតំណាងអង្គការ គសក ដើម្បីជួប ឬទាក់ទងនឹងអង្គការសមាជិក ស្ថាបន័ជាតិឬអង្គការនានា។ បុគ្គលរូបនេះត្រូវធ្វើឱ្យមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយរាល់ស្ថាប័នរដ្ឋបាលសមស្រប ទាំងក្នុង និងក្រៅរដ្ឋាភិបាលធ្វើជាខ្សែរយៈជាមួយទីភ្នាក់ងារទ្វេភាគី និងពហុភាគីដែលមានវត្តមាននៅកម្ពុជា ហើយវិភាគរករាល់លក្ខណៈដែលអាចផ្តល់ការជួយគ្នាទៅវិញទៅមក និងសហប្រតិបត្តិការរវាងគ្នានិងគ្នា ។ រាល់ការទំនាក់ទំនងជាមួយភាគីខាងក្រៅអង្គការ គសក នេះគឺត្រូវអនុវត្តតាមគោលការណ៍កំណត់ដោយគណៈកម្មាធិការប្រតិបត្តិ ។

៦) ភារកិច្ចចំបងនៃនាយក/នាយិកាប្រតិបត្តិ គឺព្យាយាមធ្វើយ៉ាងណាឱ្យបុគ្គលិកអង្គការ គសក ទាំងអស់មានកិច្ចសន្យាប្រកបការងារដែលក្នុងនេះមានចែងយ៉ាងច្បាស់លាស់អំពីភារកិច្ចនានា ព្រមជាមួយលក្ខខណ្ឌនៃការប្រកបអាជីព ។ យ៉ាងហោចណាស់មួយដង រៀងរាល់ឆ្នាំ នាយក/នាយិកាប្រតិបត្តិត្រូវធ្វើរបាយការណ៍អំពីភារកិច្ច ការប្រគល់សិទ្ធិបន្តដើម្បីធ្វើការងារ និង

លក្ខខណ្ឌនៃការប្រកបការងារនៃបុគ្គលិកអង្គការ គសក ដាក់ជូនគណៈកម្មាធិការប្រតិបត្តិដើម្បីស្នើការឯកភាព ។

៧) ភារកិច្ចចំបង នៃនាយក/នាយិកាប្រតិបត្តិ គឺគ្រប់គ្រងកិច្ចការប្រចាំថ្ងៃ និងលក្ខណៈរួមនៃការប្រកបការងារ នៃបុគ្គលិកទាំងអស់ នៃអង្គការ គសក ។ នាយកប្រតិបត្តិត្រូវព្យាយាម ធ្វើយ៉ាងណាឱ្យបុគ្គលិកអង្គការ គសក ទាំងអស់ទទួលការវាយតម្លៃអំពីការងាររបស់ខ្លួន យ៉ាងសមស្រប និងយ៉ាងទៀងទាត់ដោយផ្អែកលើគោលការណ៍ និងបទបញ្ញត្តិដែលមានកំណត់។ ទោះបីជានាយក/នាយិកាប្រតិបត្តិ ទទួលខុសត្រូវលើការជ្រើសរើស និងបញ្ឈប់បុគ្គលិកធ្វើការនៅអង្គការ គសក ទាំងអស់ នាយក/នាយិកាប្រតិបត្តិត្រូវព្យាយាមចាត់តាំងឱ្យមានបែបបទសមស្រប សម្រាប់គ្រប់គ្រងបុគ្គលិក ហើយធ្វើយ៉ាងណាឱ្យទម្រង់បែបបទនេះដំណើរការតាមការកំណត់ ។

៨) នាយក/នាយិកាប្រតិបត្តិ គឺទទួលខុសត្រូវលើសុខុមាលភាព និងសុវត្ថិភាពនៃបុគ្គលិកទាំងអស់ នៃអង្គការ គសក ហើយត្រូវពិគ្រោះជាមួយគណៈកម្មាធិការប្រតិបត្តិ (បើសិនជាសមស្រប) អំពីបញ្ហាផ្សេងៗពាក់ពន្ធ័ នឹងបុគ្គលិក ។

៩) តាមរយៈគណៈកម្មាធិការប្រតិបត្តិ នាយក/នាយិកាប្រតិបត្តិ ផ្តួចផ្តើមហើយបង្កលក្ខណៈឱ្យមានគោលការណ៍រដ្ឋបាលនានា។ នាយក/នាយិកាប្រតិបត្តិ ត្រូវស្នើការឯកភាពលើគោលការណ៍ទាំងនោះពីគណៈកម្មាធិការប្រតិបត្តិ នៃសមាជិកភាព។

១០)ទោះបីជាគណៈកម្មាធិការប្រតិបត្តិទទួលខុសត្រូវលើរាល់ការសម្រេចផ្នែកហិរញ្ញវត្ថុ និងចំណាយទាំងឡាយនៃអង្គការ គសក នាយក/នាយិកាប្រតិបត្តិមានភារកិច្ចពិនិត្យផ្ទាល់លើរាល់ទម្រង់ រដ្ឋបាល ហិរញ្ញវត្ថុ (កាលណាចាំបាច់ និងសមស្រប) លើកិច្ចការរបស់គណនេយ្យករ នៃអង្គការ គសក ។

១១) រាល់លិខិតផ្លូវការផ្ញើជូនក្រសួងនានា នៃរាជរដ្ឋាភិបាលកម្ពុជា ឬប្រមុខរដ្ឋទាមទារឱ្យមាន ហត្ថលេខានៃនាយក/នាយិកាប្រតិបត្តិ ឬប្រធានគណៈកម្មាធិការប្រតិបត្តិ។

១២) គណៈកម្មាធិការប្រតិបត្តិនឹងផ្តល់សិទ្ធិពិសេសដើម្បីចុះហត្ថលេខាដល់នាយក/នាយិកាប្រតិបត្តិ ដើម្បីកិច្ចការហិរញ្ញវត្ថុ និងលិខិតផ្សេងៗ។ ជាគោលការណ៍ កិច្ចសន្យានានានិងឯកសារ ដែលជាលក្ខណៈច្បាប់ចាត់ទុកជាផ្លូវការគឺត្រូវចុះហត្ថលេខាដោយនាយក/នាយិកាប្រតិបត្តិ។ ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការប្រតិបត្តិ ចុះហត្ថលេខា រួមជាមួយនាយក/នាយិកាប្រតិបត្តិលើឯកសារនានា។

# ប្រការ ៩: ហិរញ្ញវត្ថុ

## ៩.១ ថវិកា

ថវិការបស់អង្គការ គសក បានមកពីបង់កម្រៃសមាជិកភាពប្រចាំឆ្នាំ តាម រយៈការឧបត្ថម្ភបន្ថែមដោយអង្គការសមាជិកភាព ដៃគូអភិវឌ្ឍន៍ ពីប្រភពមូលនិធិ និងពីសកម្មភាពរកប្រាក់ចំណូលស្របច្បាប់ផ្សេងៗទៀត។

## ៩.២ ការប្រើប្រាស់ថវិកា

គណៈកម្មាធិការប្រតិបត្តិទទួលខុសត្រូវលើការប្រើប្រាស់ថវិកា ហើយត្រូវខិតខំគ្រប់គ្រងថវិកា និង អចលនៈវត្ថុរបស់អង្គការ គសក ឱ្យបានសមស្រប។ សមាជិកគណៈកម្មាធិការប្រតិបត្តិ ជាបុគ្គលក្តី ជាសមូហភាពក្តី ពុំប្រឈមមុខដោយផ្ទាល់នូវពិរុទ្ធហិរញ្ញវត្ថុផ្ទាល់ខ្លួនណា ដែលអាចមានឡើង ដោយសារការជាប់ជំពាក់នានាដែលកើតមានឡើងពាក់ពន្ធ័ជាមួយអង្គការ គសក។ អង្គការ សមាជិក ដែលជានិយោជកនៃគណៈកម្មាធិការប្រតិបត្តិ គឺមានការទទួលខុសត្រូវចំពោះការជាប់ ជំពាក់ ដែលបណ្តាលឡើងដោយអង្គការ គសក តាមលក្ខណៈ និងកម្រិតស្មើ និងសមាជិកឯទៀត ក៏ដូចជាសមាជិកគាំទ្រដែរ។

## ៩.៣ គម្រោងចំណាយថវិកា

គម្រោងចំណាយថវិកានៃឆ្នាំបន្ទាប់ត្រូវលើកពិភាក្សារាល់ឆ្នាំ នាពេលសន្និបាតប្រចាំឆ្នាំ ដើម្បីបង្ហាញ ពីតម្លាភាព គណនេយ្យភាព និងទទួលបានការគាំទ្រពីសមាជិក។

## ៩.៤ គម្រោងថវិកាប្រចាំឆ្នាំ

គម្រោងថវិកាប្រចាំឆ្នាំ គឺត្រូវរៀបចំដោយនាយក/នាយិកាប្រតិបត្តិ ដោយមានជំនួយការពី គណៈ កម្មាធិការហិរញ្ញឹកសម្រាប់បង្ហាញជូន និងសុំការអនុម័តពីគណៈកម្មាធិការប្រតិបត្តិដោយសម្លេង ភាគច្រើន ៥០% + ១ ។

## ៩.៥ ការចំណាយនានា

ក្នុងករណីមានការចំណាយនានា ដែលមានតំលៃលើសពី២០០០០០០០ រៀល ឫ ៥០០០ដុល្លារ សហរដ្ឋអាមេរិច និងមិនមានគ្រោងទុក្ខជាមុន ដែលជាហេតុធ្វើឱ្យមានការប៉ះពាល់ដល់ការផ្តល់ សេវាកម្មទាំងឡាយ ឬរាំងស្ទះដល់សកម្មភាពនានា ដែលបានកំណត់ជាមុន នាយក/នាយិកា ប្រតិបត្តិ ចាំបាច់ត្រូវសុំការឯកភាពពីគណៈកម្មាធិការប្រតិបត្តិ ជាមុន ក្នុងសំលេងគាំទ្រ៥០% + ១ ។

## ៩.៦ កម្រៃសមាជិកភាព

៩.៦.១ កម្រៃសមាជិកភាពប្រចាំឆ្នាំ គឺត្រូវកំណត់យកតាមផលគុណនៃគម្រោងថវិកាប្រចាំឆ្នាំជាក់ស្តែងនៃ សមាជិកដែលបានអនុម័តរួចហើយគុណជាមួយនឹងមេគុណ ០,០០២២៥។ លទ្ធផលជាក់ស្តែង នៃ ផលគុណ គឺជាចំនួនកម្រៃសមាជិកប្រចាំឆ្នាំដែលត្រូវបង់ ប៉ុន្តែមិនឱ្យយកលើសពីចំនួនអតិបរមាគឺ ១២០០០០០០ រៀល ឫ ៣០០០ដុល្លាសហរដ្ឋអាមេរិកឡើយ។

៩.៦.២ ចំពោះអង្គការសមាជិកគាំទ្រ តម្រូវឱ្យបង់វិភាគទានសមាជិកភាពត្រឹម ចំនួន៧៥%នៃសមាជិកពេញ សិទ្ធិ ។

៩.៦.៣ អង្គការសង្គមស៊ីវិលថ្មី ដែលបានដាក់ពាក្យសុំចូលជាសមាជិកភាព តម្រូវឱ្យបង់កម្រៃ ២០០០០០ រៀល ឫ ៥០ ដុល្លាសហរដ្ឋអាមេរិក ជាកម្រៃនៃការត្រួតពិនិត្យឯកសារ និងការចូលរួមក្នុងសកម្មភាព នានាដូចមានចែងនៅក្នុងលក្ខន្តិកៈ ក្នុងនាមជាសមាជិកសង្កេតរបស់អង្គការ គសក ។

៩.៦.៤ កម្រៃសមាជិកភាពប្រចាំឆ្នាំ គឺត្រូវបង់ចាប់ក្នុងចន្លោះពេលពីថ្ងៃទី ២ ខែ មករា ដល់ថ្ងៃទី៣០ខែមិនា ឬយ៉ាងយូរបំផុតនៅខែទី៣នៃឆ្នាំសារពើពន្ធថ្មីរបស់អង្គការសមាជិកសាមី ជារៀងរាល់ឆ្នាំ យោងតាមគោលការណ៍ ៩.៦.១.ដល់ ៩.៦.២ នៃប្រការ៩នេះ ។

### ៩.៧ ការវៃអង្គាសថវិកា

រាល់ការវៃអង្គាសថវិកា សម្រាប់មូលហេតុផេង្សៗ គឺត្រូវផ្តួចផ្តើម និងមានការឯកភាពពីគណៈកម្មាធិការប្រតិបត្តិ ។

### ៩.៨ អំណោយពីប្រភពដែលពុំមែនជាសមាជិកអង្គការ

រាល់ការទទួលអំណោយជាសាច់ប្រាក់ (Cash donations) ឬជាសំភារៈ (in kind donation) ពីប្រភពដែលពុំមែនជាសមាជិកអង្គការ គឺចាំបាច់ត្រូវមានការឯកភាពពីគណៈកម្មាធិការប្រតិបត្តិ ។

### ៩.៩ របាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆមាស និងប្រចាំឆ្នាំគឺត្រូវផ្សព្វផ្សាយជូនដល់គ្រប់អង្គការសមាជិក ។

### ៩.១០ ការធ្វើសវនកម្ម

ការធ្វើសវនកម្ម ឬការត្រួតពិនិត្យបញ្ជីហិរញ្ញវត្ថុៈ នាយក/នាយិកាប្រតិបត្តិទទួលបន្ទុកបង្កលក្ខណៈឱ្យមានការចុះត្រួតពិនិត្យ បិទបញ្ជីហិរញ្ញវត្ថុប្រចាំឆ្នាំ។ ក្រុមអ្នកចុះត្រួតពិនិត្យ ត្រូវមានការទទួលស្គាល់ និងសម្រេចពីគណៈកម្មាធិការប្រតិបត្តិ។ របាយការណ៍នៃអ្នកត្រួតពិនិត្យបិទបញ្ជី និង ឯកសារអំពីការគ្រប់គ្រងគឺត្រូវផ្ញើជូនគណៈកម្មាធិការប្រតិបត្តិ និងអង្គការសមាជិក។

## ប្រការ ១០: ការរំលាយ និងការចាត់ចែងទ្រព្យសម្បត្តិនៅពេលដែលត្រូវរំលាយអង្គការ

### ១០.១ ការរំលាយអង្គការ

អង្គការ គ.ស.ក នឹងអាចរំលាយបានលុះត្រាតែមានសម្លេងគាំទ្រលើសពី៥០ភាគរយ (៥០%+១) នៃ អង្គការសមាជិកភាពទាំងអស់របស់ខ្លួនតាមរយៈការបោះឆ្នោត ។

### ១០.២ ការចាត់ចែងទ្រព្យសម្បត្តិនៅពេលដែលត្រូវរំលាយអង្គការ

គណៈកម្មាធិការប្រតិបត្តិនៃអង្គការ គ.ស.ក ដោយមានកិច្ចសហការពីនាយក/នាយិកាប្រតិបត្តិ នឹងដើរតួនាទីចាត់ចែងការសំអាតបញ្ជីពាក់ពន្ធ័នានា ការទូទាត់សំណងនានា និងការប្រគល់ទ្រព្យសម្បត្តិ ដូចមាននៅក្នុងបញ្ជីសារពើភ័ណ្ឌរបស់អង្គការឱ្យទៅម្ចាស់ជំនួយវិញ ឬក៏ប្រគល់ឱ្យទៅអង្គការផ្សេងទៀត ដោយមានការព្រមព្រៀងពីម្ចាស់ជំនួយជាលាយលក្ខ័អក្សរ ។

## ប្រការ ១១: ការធ្វើវិសោធនកម្មលក្ខន្តិក

១១.១ រាល់សំណើកែប្រែគោលការណ៍ត្រូវឆ្លងកាត់សមាជិកភាពតាមរយៈគណៈកម្មាធិការប្រតិបត្តិ ក្នុងករណីដូចខាងក្រោម ៖

ក) គណៈកម្មាធិការប្រតិបត្តិ លើកសំណើ

ខ) ការទទួលឯកសារអំពីការស្នើសុំកែប្រែដែលមានសម្លេង ១០% នៃសមាជិកភាពសរុប ហើយដែលបញ្ជាក់ដោយការចុះហត្ថលេខាគាំទ្រភ្ជាប់ជាមួយ។

១១.២ រាល់ការស្នើសុំកែប្រែគោលការណ៍ត្រូវដាក់ជូនគណៈកម្មាធិការប្រតិបត្តិ យ៉ាងហោចណាស់១៥ ថ្ងៃមុនការប្រជុំប្រចាំពីរខែម្តងជាមួយសមាជិក សម្រាប់ជូនសមាជិកភាពពិនិត្យ និងចែកចាយ។

១១.៣ សំណើកែប្រែទាំងនេះ នឹងត្រូវលើកមកពិភាក្សាក្នុងកិច្ចប្រជុំប្រចាំពីរ (២) ខែម្តង ហើយការវិភាគអំពីការកែប្រែនេះ ព្រមជាមួយការបោះឆ្នោតអនុម័តការកែប្រែនេះ គឺនិងធ្វើឡើងក្នុងកិច្ចប្រជុំនៃពីរខែបន្ទាប់។

១១.៤ គោលការណ៍អាចកែប្រែបានលុះត្រាណាតែមានការគាំទ្រសំណើកំណែនេះ ដោយសម្លេង លើសពី ៥០ភាគរយ ឬ ៥០% + ១ នៃចំនួនអង្គការសមាជិកទាំងអស់។

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge

**ទស្សនវិស័យ:** ការអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់ប្រទេសកម្ពុជា
**Vision:** Sustainable development for Cambodia

គោរពជូន: គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

កម្មវត្ថុ: លក្ខន្តិកៈកែសម្រួល

សូមគោរពគណៈកម្មាធិការប្រតិបត្តិជាទីគោរព!
ដោយថ្មីៗនេះលក្ខន្តិកៈកែសម្រួលត្រូវបានអនុម័តដោយសមាជិកជាង ២/៣ នៃសមាជិកសរុបរួចរាល់ហើយ ទន្ទឹមនឹងនោះយើងក៏បានរួមបញ្ចូលនូវរាល់មតិយោបល់ទាំងអស់របស់សមាជិករបស់ យើងរួចរាល់ហើយដែរ។

ក្នុងន័យនេះខ្ញុំបាទសូមបញ្ជូន លក្ខន្តិកៈកែសម្រួល នេះដើម្បីស្នើសុំការអនុម័តពីគណៈកម្មាធិការប្រតិបត្តិទាំងអស់ដើម្បីទុកជាឯកសារផ្លូវការ។

សូមគណៈកម្មាធិការប្រតិបត្តិទទួលនូវការគោរពពីខ្ញុំ និងសុំផ្តល់នូវការអនុម័តតាមការគួរ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ៨ ខែសីហា ឆ្នាំ២០១៤

ដោយក្តីគោរព

សឿង សារឿន

នាយកប្រតិបត្តិ



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
15/01/2009 GPP 24/11/2014
Symbol of Trust

ថ្ងៃ ខែ ឆ្នាំ កំណែប្រែ: ៨ សីហា ២០១៩
បានឃើញនិង ឯកភាពដោយគណៈកម្មាធិការប្រតិបត្តិ

| ល.រ | ឈ្មោះ តួនាទី អង្គការ | ហត្ថលេខា |
|---|---|---|
| ១ | **វេជ្ជបណ្ឌិត សុខ ឌីម**<br>ប្រធានគណៈកម្មាធិការប្រតិបត្តិ<br>នាយកប្រតិបត្តិ<br>គណៈកម្មាធិការសុខភាពដើម្បីកម្ពុជា | |
| ២ | **រីឆាត វីនធីថុន**<br>អនុប្រធានគណៈកម្មាធិការប្រតិបត្តិ<br>អ្នកអភិវឌ្ឍកម្មវិធី និង ផ្តល់ដំបូន្មានផ្នែកទំនាក់ទំនង<br>វីអេសអូ | Richard m. Witt |
| ៣ | **ប៊ូ មល្លិកា**<br>ហិរញ្ញឹកគណៈកម្មាធិការប្រតិបត្តិ<br>អ្នកសម្របសម្រួលកម្មវិធី<br>អ្នកស្ម័គ្រចិត្តអូស្ត្រាលីអន្តរជាតិ | |
| ៤ | **កែវ គៀង**<br>សមាជិកគណៈកម្មាធិការប្រតិបត្តិ<br>នាយិកាប្រចាំប្រទេស<br>ហេហ្វឺកម្ពុជា | |
| ៥ | **រស់ សុភាព**<br>សមាជិកគណៈកម្មាធិការប្រតិបត្តិ<br>នាយិកាប្រតិបត្តិ<br>យេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា | |
| ៦ | **អឺន ជើចេនសឺន**<br>សមាជិកគណៈកម្មាធិការប្រតិបត្តិ<br>អ្នកតំណាងប្រចាំប្រទេស<br>ដាន់មីសសិន | E. Jürg |
| ៧ | **ណុប វ៉ាន់ធី**<br>សមាជិកគណៈកម្មាធិការប្រតិបត្តិ<br>អ្នកផ្តល់ដំបូន្មាន សម្រាប់នាយកប្រចាំប្រទេស<br>ទស្សនៈពិភពលោកប្រចាំកម្ពុជា | N. Vanthy |

**ទស្សនៈវិស័យ :**
ការអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់ប្រទេសកម្ពុជា.

**បេសកកម្ម :**
យើងផ្តល់នូវសេវាកម្មប្រកបដោយគុណភាពខ្ពស់ជូនដល់សង្គមស៊ីវិល និងបង្កលក្ខណៈអោយមានឥទ្ធិពល ទៅដល់តួអង្គអភិវឌ្ឍ នៅក្នុងប្រទេសកម្ពុជា.

**គុណតម្លៃ :**
- ★ សុចរិតភាព
- ★ ភាពឆ្លើយតប
- ★ កិច្ចសហប្រតិបត្តិការ
- ★ គុណភាព
- ★ បរិយាប័ន

**គោលដៅ:**
សង្គមស៊ីវិលមួយដែលមានកិច្ចសហការដ៏រឹងមាំ និងមានសមត្ថភាពឆ្លើយតបទៅនឹងបញ្ហានៃការអភិវឌ្ឍនៅកម្ពុជា


ផ្ទះលេខ ៩-១១, ផ្លូវ ៤៧៦ ទួលទំពូង ១, ចំការមន
ប្រអប់សំបុត្រ ៨៥៥, ភ្នំពេញ, កម្ពុជា.
ទូរស័ព្ទ: +៨៥៥ ២៣ ២១៤ ១៥២
ទូរសារ +៨៥៥ ២១៦ ០០៩
សារអេឡិចត្រូនិច : info@ccc-cambodia.org
www.ccc-cambodia.org
www.facebook.com/CCCsince1990
www.youtube.com/CCCambodia